# ការសម្ភាសន៍របស់បងស្រី ព្រីង ធីនឹងអ៊ុំស្រី ព្រីង ថៃ

កៈ អ្នកសម្ភាសន៍គេ រត្ន ពិសី ខៈ អ្នកដែរគេត្រូវសម្ភាសន៍ ព្រីង ធីនិងព្រីង ថៃ

**ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់បងស្រី ព្រីងធីនឹងអ៊ុំស្រី ព្រីងថៃ**

ធ្វើឡើងនៅភូមិខ្ពប ឃុំ កោះឧកញ៉ាតី ស្រុក ខ្សាច់កណ្ដាល កណ្ដាល ធ្វើឡើងនៅថ្ងៃទី ០៩ ខែ ០៦ ឆ្នាំ ២០១៨។ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់បងស្រី ព្រីង ធីនិងអ៊ុំស្រី ព្រីង ថៃហើយគាត់បានធ្លាប់ឆ្លងកាត់នៅឧបសគ្គជាច្រើននៅក្នុងជីវិតរបស់គាត់ហើយគាត់ទាំងនិងមានការលំបាកអត់បានរៀនសូត្រព្រោះក្រុមគ្រួសារមានជីវភាពក្រខ្សត់មិនអាចឲ្យគាត់ទៅរៀនបានឡើយហើយគាត់នៅមើលប្អូននៅផ្ទះហើយពេលដែលគាត់មានគ្រួសារគាត់បានជួបនៅរឿងជាច្រើនទៀតដោយប្ដីមិនយល់ចិត្តហើយចេះតែរករឿងគាត់ហើយគាត់បានសម្រេចចិត្តលែងគ្នាចេញផ្លូវគ្នាដើររៀងខ្លួន។ហើយគាត់ខំប្រឹងជំណាស់គ្រាប់ឧបសគ្គដើម្បីចិញ្ចឹមកូនហើយឲ្យកូនរៀនការត្បាញពីគាត់ដើម្បីចិញ្ចឹមខ្លួនឯងហើយនិងកូន។ហើយគាត់ទាំងពីរជាមនុស្សស្លូតហើយមានការរុសរាយរាក់ទាក់និងមានការស្រឡាញ់អ្នកជិតខាងផងដែរ។

កៈ ហើយអញ្ចឹងជាដំបូងខ្ញុំសូមជំរាប់សួរអ៊ុំហើយនឹងបងស្រីខ្ញុំបាទមានឈ្មោះថា រត្ន ពិសីហើយខ្ញុំសូមអនុញ្ញាតអ៊ុំហើយនិងបងស្រីធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់អ៊ុំហើយនឹងបងស្រីហើយខ្ញុំធ្វើឡើងដោយសារសាកលវិទ្យាល័យមួយដែរមានឈ្មោះថាសាកលវិទ្យាល័យ BYU
ហើយដែលមានទីតាំងនៅសហរដ្ឋអាមេរិចហើយដើម្បីថែរក្សាជីវប្រវត្តិរបស់អ៊ុំស្រីហើយនិងបងស្រីហើយដើម្បីថែរក្សាជីវប្រវត្តិរបស់ជីដូនជីតារបស់អ៊ុំស្រីហើយទុកឲ្យកូនចៅជំនាន់ក្រោយហើយឲ្យគាត់បានដឹងថាអ្នកជំនាន់មុនមានការលំបាកហើយមានជួបឧបសគ្គជាច្រើននៅក្នុងជីវិតរបស់អ៊ុំស្រីហើយនិងបងស្រីហើយឲ្យមានការតស៊ូណាអ៊ុំស្រីហើយនិងបងស្រី។ហើយខ្ញុំធ្វើឡើងនៅថ្ងៃទី ០៩ ខែ ០៦ ឆ្នាំ
២០១៨។ហើយអត់ទោសបងស្រីហើយនិងអ៊ុំស្រីមានឈ្មោះអីដែរ?
ខៈ ខ្ញុំឈ្មោះ ព្រីង ថៃ។
កៈ ហើយអញ្ចឹងបងស្រីមានឈ្មោះអីដែរបងស្រី?
បងស្រីៈ ខ្ញុំឈ្មោះព្រីង ធី។
កៈ បាទ!ហើយអញ្ចឹងបងស្រីមានឈ្មោះព្រីង
ធី។ហើយអញ្ចឹងបងស្រីមានឈ្មោះខាងក្រៅទេ?ហើយនិងអ៊ុំស្រីមានឈ្មោះខាងក្រៅទេ?
ខៈ អត់មានទេមានឈ្មោះនិងតែមួយនិង។
កៈ បាទ! ហើយបងស្រី។
បងស្រីៈ អត់មានទេ។
កៈ បាទ! អត់មានឈ្មោះហៅខាងក្រៅដូចគេហៅអីផ្សេងអត់មានទេអ៊ុំស្រី។

ខ៖ អត់មានទេមានគេហៅឈ្មោះនិងតែមួយនិង។
ក៖ បាទ! មានឈ្មោះតែមួយនិង។
បងស្រី៖ ចាំ!
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងអ៊ុំស្រីហើយនិងបងស្រីមានចាំឆ្នាំកំណើតផ្ទាល់ទេ?
ខ៖ ខ្ញុំភ្លេចហើយនាត។
ក៖ បាទ! ហើយអញ្ចឹងមានដឹងថាអ៊ុំកើតនៅឆ្នាំណាទេអ៊ុំស្រី?
ខ៖ អត់ដឹង។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំស្រីអត់ដឹងទេ។ហើយអញ្ចឹងបើឆ្នាំខ្មែរយើងនិងអ៊ុំចាំទេអ៊ុំស្រី?
ខ៖ អត់ចាំផងនិង។
ក៖ បាទ! ហើយអញ្ចឹងមិចអត់ចាំអញ្ចឹងអ៊ុំស្រី?
ខ៖
ហើយកាលពីជំនាន់អត់ថាដូចគ្រលប់គ្រលឹនអត់ហើយខ្ញុំអត់បានរៀនបានសូត្រអីផងនិង។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំដឹងថាអ៊ុំកើតឆ្នាំដូចជូត ឆ្លូវ ខាល ថោះអីទេអ៊ុំស្រី?
ខ៖ ហើយបើនិងខ្ញុំចាំតានិងបានខ្ញុំដឹងថាឆ្នាំអី។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំមានឆ្នាំអីដែរអ៊ុំស្រី?
ខ៖ ខ្ញុំឆ្នាំ ឆ្លូវ ។
ក៖ ហើយអញ្ចឹងអ៊ុំឆ្នាំ ឆ្លូវ។
ខ៖ ចាំ!
ក៖ បាទ!ហើយអញ្ចឹងអ៊ុំស្រីមានអាយុ៥០ជាងហើយអ៊ុំស្រី?
ខ៖ ចាំ! ខ្ញុំរាល់ថ្ងៃនិងខ្ញុំជិត៦០ហើយ។
ក៖ បាទ!
ហើយអញ្ចឹងរាល់ថ្ងៃនិងអ៊ុំស្រីជិត៦០ហើយ។ហើយអញ្ចឹងបងស្រីមានឆ្នាំអីដែរបងស្រី?
បងស្រី៖ ខ្ញុំឆ្នាំ ខាល ។
ក៖ បាទ! ហើយអញ្ចឹងបងស្រីមានឆ្នាំ មមែបងស្រី?
បងស្រី៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងបងស្រីមានចាំថ្ងៃខែឆ្នាំកំណើតបងស្រីណាទេ?
បងស្រី៖ ខ្ញុំអត់ចាំទេទាល់តែខ្ញុំមើលបញ្ជីរជាតិ។
ក៖ បាទ! ហើយអញ្ចឹងទាល់តែមើលបញ្ជីរជាតិ។
ខ៖ ហើយខ្ញុំនិងវានិងម្តាយខ្ញុំអត់ដឹងថាគាត់យកទៅទុកកន្លែងណា។
ក៖
ហើយអញ្ចឹងបងស្រីឆ្នាំមមែហើយអញ្ចឹងអ៊ុំស្រីហើយនិងបងស្រីមានឆ្នាំទីកន្លែងកំណើតរបស់អ៊ុំស្រីហើយនិងបងស្រីទេ?
ខ៖ ចាំតា។

ក៖ បាទ! នៅណាដែរអ៊ុំស្រី?
ខ៖ នៅកោះឧកញ៉ាតីនិងម៉ង។
ក៖ បាទ! នៅនិងម៉ងអ៊ុំស្រី។
ខ៖ ចាំ! នៅនឹងម៉ង។
ក៖ ហើយអញ្ជឹងបងស្រីនៅនិងដែរ។
ខ៖ ខ្ញុំកើតមកនៅនិងម៉ង។
បងស្រី៖ ចាំ! ខ្ញុំនៅនឹងម៉ងនិង។
ក៖ បាទ! ហើយអញ្ជឹងនៅនិងជាមួយគ្នាទៅ។
ខ៖ ចាំ!
បងស្រី៖ ចាំ!
ក៖ ហើយអញ្ជឹងអ៊ុំស្រីនៅនិងគេហៅភូមិអីគេដែរអ៊ុំស្រី?
ខ៖ នៅនិងគេហៅភូមិ ខ្ពប ។
ក៖ បាទ! គេហៅភូមិ ខ្ពប ហើយអញ្ជឹងឃុំអីគេដែរអ៊ុំស្រី?
ខ៖ ភូមិ ខ្ពប ឃុំកោះឧកញ៉ាតី។
បងស្រី៖ ភូមិ ខ្ពប ឃុំកោះឧកញ៉ាតី។
ក៖ បាទ! ហើយអញ្ជឹងស្រុកខ្សាច់កណ្តាល ខេត្ត កណ្តាល។
ខ៖ ចាំ!
បងស្រី៖ ចាំ!
ក៖ ហើយអញ្ជឹងបើនិយាយពីបងប្អូនបង្កើតមានប៉ុន្មាននាក់ដែរអ៊ុំស្រី?
ខ៖ ហើយបើបងប្អូនបង្កើតនិងមាន៨នាក់។
បងស្រី៖ បងប្អូនខ្ញុំមាន៨នាក់។
ខ៖ អត់ទេមាន៥នាក់តែស្លាប់អត់មួយនាក់។
បងស្រី៖ យើងនិយាយថាមាន៨នាក់ទៅណាស់។
ក៖ បាទ! ហើយអញ្ជឹងបងប្អូនបង្កើតមាន៨នាក់។
ខ៖ ចាំ! ស្លាប់អស់មួយ។
ក៖ បាទ! ហើយអញ្ជឹងស្លាប់អស់មួយ។
បងស្រី៖ ចាំ!
ក៖ ហើយអញ្ជឹងបងកូនទីប៉ុន្មានដែរបងស្រី?
បងស្រី៖ ខ្ញុំកូន៣។
ក៖ បាទ!
បងស្រីកូន៣គេអញ្ជឹងបានស្គាត់បងស្រី។ហើយអញ្ជឹងបងស្រីមានចាំឈ្មោះបងប្អូនរបស់ប្អូនរបស់អ៊ុំស្រីទេ។ហើយអញ្ជឹងអ៊ុំស្រីកូនទីប៉ុន្មានដែរ?
ខ៖ ខ្ញុំកូនទី១នឹង។

កៈ បាទ! ហើយអញ្ចឹងអ៊ុំស្រីកូនទី១អ៊ុំស្រី។ហើយអញ្ចឹងអ៊ុំស្រីចាំប្អូនរបស់អ៊ុំដែរណោះអ៊ុំស្រី?
ខៈ ចាំ!
កៈ បាទ! ហើយអញ្ចឹងប្អូនទីមួយរបស់អ៊ុំមានឈ្មោះអីដែរ។
ខៈ ប្អូនខ្ញុំមានឈ្មោះ ព្រួច។
កៈ បាទ! គាត់មានឈ្មោះ ព្រួច។
ខៈ ចាំ! ឈ្មោះព្រួចនិងគាត់បានស្លាប់ហើយ។
កៈ បាទ! ហើយអញ្ចឹងឈ្មោះព្រួចនិងគាត់បានស្លាប់ហើយអ៊ុំស្រី?
ខៈ ចាំ!
កៈ ហើយអញ្ចឹងគាត់ស្លាប់នៅជំនាន់អាពតនិងទៅអ៊ុំស្រី?
ខៈ គាត់ស្លាប់នៅជំនាន់ឥឡូវនិង។
បងស្រីៈ គាត់ស្លាប់នៅជំនាន់និង។
កៈ បាទ! ហើយអញ្ចឹងគាត់ស្លាប់ដោយសារអីដែរអ៊ុំស្រី?
ខៈ គាត់កើតឈឺគេហៅថាមហារីក។
កៈ បាទ! ហើយអញ្ចឹងមហារីកសួតឬមហារីកថ្លើមអ៊ុំស្រី?
ខៈ ចាំ!គាត់មានជម្ងឺមហារីកថ្លើមនិង។
កៈ បាទ! គាត់មហារីកថ្លើមអ៊ុំស្រី។
ខៈ ចាំ!
កៈ ហើយអញ្ចឹងគាត់ស្រីឬក៏ប្រុសអ៊ុំស្រី?
ខៈ ប្រុស។
កៈ បាទ! គាត់ប្រុស។ហើយអញ្ចឹងប្អូនទី៣មានឈ្មោះអីគេអ៊ុំស្រី?
ខៈ ហើយទី៣មានឈ្មោះ យ៉ុង ។
កៈ បាទ! ទី៣មានឈ្មោះ យ៉ុង ។ហើយអញ្ចឹងប្រុសដែរ។
ខៈ ចាំ!ប្រុសដែរ។
កៈ បាទ! ហើយអញ្ចឹងប្រុសប៉ុន្មានហើយស្រីប៉ុន្មានដែរអ៊ុំស្រី?
ខៈ ប្រុសពីរស្រីពីរ។
កៈ បាទ! ហើយអញ្ចឹងប្រុសពីរស្រីពីរ។
ខៈ ចាំ!
កៈ ហើយគាត់ដែរមានឈ្មោះ យ៉ុងនិងគាត់នៅនឹងតាអ៊ុំស្រី?
ខៈ ចាំ! គាត់នៅនឹងតា។ហើយគាត់នៅចុងកោះ។
កៈ បាទ! ហើយអញ្ចឹងគាត់នៅចុងកោះហើយអ៊ុំនៅកណ្តាលកោះ។
ខៈ ហើយខ្ញុំនៅ ខ្ពបហើយគាត់នៅយកប្រពន្ធនៅនឹង។

កៈ បាទ!
ហើយអញ្ចឹងអ៊ុំមានចាំសាច់រឿងជាមួយពួកគាត់ទេ។ហើយបងស្រីមានចាំសាច់រឿងជាមួយបងៗអត់បងស្រី។
បងស្រីៈ ខ្ញុំចាំតា។
កៈ បាទ!
ហើយបងស្រីដូចធ្លាប់ទៅណាជាមួយគ្នាហើយបានធ្វើអីជាមួយគ្នាអញ្ចឹងបងស្រីហើយនៅជំនាន់អាពតហើយធ្លាប់រត់ជាមួយគ្នាអញ្ចឹង។
ខៈ ចាំ! បើនៅជំនាន់អាពតនិងវាអត់បានរត់ទេហើយខ្ញុំទេជាអ្នករត់នោះ។
បងស្រីៈ ចាំ! ពេលនិងខ្ញុំអត់ទាន់កើតផងនិង។
ខៈ ខ្ញុំរត់ពីកោះនិងទៅរហូតដល់ពាក់កណ្ដាលព្រៃពោធនិងណាស់។
កៈ បាទ!
ខៈ ខ្ញុំដើរទៅរហូតអញ្ចឹងណាស់ហើយខ្ញុំដើរដល់ទៅបីយប់បីថ្ងៃបានដល់។
កៈ បាទ!
ហើយអញ្ចឹងពេលនិងអ៊ុំស្រីថាពេលដែរអ៊ុំស្រីនៅជំនាន់និងអ៊ុំស្រីមានអាយុប៉ុន្មានដែរអ៊ុំស្រី?
ខៈ ហើយកាលពេលនិងប្រហែលជាអាយុ១៧ទៅ១៨ឆ្នាំហើយ។
កៈ បាទ! ហើយអញ្ចឹងអ៊ុំនៅអាយុប៉ុន្មាននិងពាលពេញកម្លាំងហើយអញ្ចឹងអ៊ុំស្រី។
ខៈ ចាំ!
កៈ បាទ! ហើយអញ្ចឹងគេហៅទៅកងចល័តហើយអញ្ចឹង។
ខៈ ចាំ! នឹងហើយពេលនិងចំពេញ។
កៈ បាទ! ពេលនិងចំពេញហើយអញ្ចឹងអ៊ុំស្រី?
ខៈ ចាំ!
កៈ បាទ! ហើយអញ្ចឹងកាលនិងគេឲ្យអ៊ុំស្រីទៅជីកដីធ្វើស្រែចំការទៅអ៊ុំស្រី?
ខៈ
ចាំ!នឹងហើយគេឲ្យខ្ញុំទៅជីកដីហើយហើយនិងធ្វើស្រែចំការនិងហើយ។ហើយគេឲ្យខ្ញុំទៅដល់វិហារសួគ៌និង។
កៈ បាទ!នឹងហើយពេលនិងអ៊ុំស្រីពាលពេញកម្លាំងហើយគេប្រើនិងអ៊ុំស្រី?
ខៈ ចាំ!
កៈ បាទ!ហើយកាលនិងអ៊ុំស្រីមានអាយុ១៨ទៅ១៩ឆ្នាំ។
ខៈ ចាំ! កាលនឹងខ្ញុំមានអាយុ១៨ទៅ១៩ឆ្នាំនិង។
កៈ ហើយដូចកូនក្មេងនិងគេឲ្យគាបអាចម៍គោនិង។
ខៈ ចាំ!
កៈ ហើយបើធំៗអញ្ចឹងអីគេឲ្យជីកដី។
ខៈ ទៅមុខហើយ។
កៈ បាទ! ហើយទៅធ្វើស្រែធ្វើអីទៅអ៊ុំស្រី?

ខ៖ ចាំ!
ក៖ ហើយអញ្ចឹងអ៊ុំមានចាំឈ្មោះឪពុកម្ដាយរបស់អ៊ុំទេ?
ខ៖ ខ្ញុំចាំតា។
ក៖ បាទ! ហើយគេមានឈ្មោះអ្វីដែរ?ហើយអញ្ចឹងអ្នកម្ដាយមានឈ្មោះអីដែរ?
ខ៖ ហើយម្ដាយខ្ញុំមានឈ្មោះ ថើត។
ក៖ បាទ! ឈ្មោះអីដែរអ៊ុំស្រី?
ខ៖ ឈ្មោះយាយ ថើត។
ក៖ បាទ! ហើយអញ្ចឹងលោកឪពុកមានឈ្មោះអីដែរអ៊ុំស្រី?
ខ៖ ឪពុកខ្ញុំមានឈ្មោះ ព្រីង ។
ក៖ បាទ! គាត់មានឈ្មោះ ព្រីង
។ហើយអញ្ចឹងអ៊ុំមានចាំថាគាត់មានឈ្មោះហៅក្រៅអត់អ៊ុំស្រី?
បងស្រី៖ អត់មានទេ។
ខ៖ អត់មានទេ។
ក៖ បាទ! ហើយគាត់មានទេ។
ខ៖ ចាំ!
បងស្រី៖ ចាំ!
ក៖ បាទ!
ខ៖ ហើយគាត់គេហៅគាត់ថា ព្រីងនិងម៉ង។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំស្រីពេលដែរគាត់ស្លាប់និងគាត់មានប្រជន្មប៉ុន្មានដែរអ៊ុំស្រី?
បងស្រី៖ ប៉ាខ្ញុំគាត់មានប្រជន្ម៧៩ឆ្នាំ។
ក៖ បាទ! គាត់មានប្រជន្ម៧៩ឆ្នាំ។
បងស្រី៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងចំពោះអ្នកម្ដាយគាត់មានប្រជន្មប៉ុន្មានដែរអ៊ុំស្រី?
ខ៖ បើម៉ែខ្ញុំគាត់មានប្រជន្ម៧០។
ក៖ បាទ! គាត់មានប្រជន្ម៧០គត់អ៊ុំស្រី?
ខ៖ ចាំ!
ក៖ បាទ!គាត់មានប្រជន្ម៧០។បាទ! ហើយអញ្ចឹងគាត់ស្លាប់ចប់អាពតហើយតាអ៊ុំស្រី?
ខ៖ ហើយគាត់ទើបតែស្លាប់ឥឡូវៗនិងដែរនិង។
បងស្រី៖ ចាំ! គាត់ទើបស្លប់ឥឡូវៗនិងដែរ។
ក៖ គាត់ទើបស្លាប់ឥឡូវនិងដែរនិង។
ខ៖ ម្ដាយខ្ញុំគាត់ស្លប់មុខ។
ក៖ បាទ! ហើយអញ្ចឹងអ្នកម្ដាយគាត់បានស្លាប់មុខលោកឪពុក។
បងស្រី៖ ចាំ!
ខ៖ ចាំ!

កៈ បាទ! ហើយលោកឪពុកគាត់ស្លាប់ប៉ុន្មានឆ្នាំដែរ?
បងស្រីៈ ប៉ាខ្ញុំគាត់ស្លាប់៣ឆ្នាំហើយ។
កៈ គាត់ទើបស្លាប់ឆាប់ៗនិងដែរនិង។
បងស្រីៈ ចាំ!
កៈ បាទ! គាត់ស្លាប់ដោយសារជម្ងឺឬក៏គាត់ស្លាប់ដោយសារអីផ្សេងអ៊ុំស្រី?
អ៊ុំស្រីៈ គាត់ស្លាប់ដោយសារជម្ងឺចាស់គាត់និង។
កៈ បាទ! ជម្ងឺចាស់អ៊ុំស្រី។
ខៈ ចាំ!
កៈ បាទ! ហើយអញ្ចឹងអ្នកម្ដាយវិញគាត់ស្លាប់ដោយសារជម្ងឺចាស់ដែរទៅ។
ខៈ ចាំ!
កៈ បាទ! ហើយអញ្ចឹងអ្នកម្ដាយគាត់អាយុបងលោកឪពុក។
ខៈ អត់ទេម្ដាយខ្ញុំប្អូនប៉ាខ្ញុំពីរឆ្នាំ។ព្រោះអី ខោលហើយនិងជូត។
កៈ បាទ!
ខៈ ព្រោះអីឪពុកខ្ញុំគាត់ឆ្នាំ ជូត ហើយម្ដាយខ្ញុំឆ្នាំ ខោល ។
កៈ បាទ! ហើយអញ្ចឹងអ៊ុំមានចាំថ្ងៃខែឆ្នាំកំណើតរបស់គាត់ទេ។
ខៈ អត់ចាំសោះ។
កៈ បាទ! អត់ចាំទេ។ហើយអញ្ចឹងបានត្រឹមចាំឆ្នាំ ជូតហើយនិងឆ្នាំខោល។
ខៈ ចាំ! បានត្រឹមចាំឆ្នាំតែប៉ុណ្ណឹងទេ។
កៈ ហើយអញ្ចឹងទីកន្លែងរបស់គាត់ថាគាត់កើតនៅកន្លែងណាទេអ៊ុំស្រី?
ខៈ បើម្ដាយខ្ញុំគាត់កើតនៅកោះនិងម៉ងហើយបើប៉ាគាត់កើតនៅស្រុក ផ្អាវនៅស្គន់។
កៈ បាទ! ហើយអញ្ចឹងគាត់កើតនៅស្រុកផ្អាវស្គន់ហើយអញ្ចឹងគាត់ស្រុកកំពង់ចាម។
ខៈ ចាំ! គាត់អ្នកស្រុកកំពង់ចាមនិង។
កៈ បាទ!
ហើយអញ្ចឹងអ្នកកំពង់ចាមមកស្រឡាញ់អ្នកខេត្តកណ្ដាលហើយអញ្ចឹងមិនមែនស្នេហាឆ្លងដែនទេមានតែឆ្លងសមុទ្រ។
ខៈ ចាំ! ឆ្លងសមុទ្រនឹងហើយ។
កៈ បាទ!
ហើយអញ្ចឹងអ៊ុំមានចាំថាគាត់ប្រកបមុខរបរអីដើម្បីចិញ្ចឹមអ៊ុំហើយនិងប្អូនៗអ៊ុំអញ្ចឹងណាស់
។
ខៈ ឪពុកខ្ញុំ។
កៈ បាទ!
ខៈ
ហើយពីដើមគាត់មិនទាន់បានម្ដាយខ្ញុំហើយម្ដាយខ្ញុំគាត់នៅស៊ីឈ្នួលគេនៅព្រែកលៀបនិង

ហើយគាត់ឃើញម៉ែខ្ញុំនិងហើយគាត់ចង់បានម៉ែខ្ញុំនិងហើយបានគាត់មករកស៊ីធ្វើកាណូត ធ្វើអីនិង។
ក៖ បាទ! ហើយអញ្ចឹងលោកឪពុករបស់អ៊ុំជាអ្នកធ្វើកាណូត។
ខ៖ ចា៎! ហើយគាត់ស៊ីឈ្នួលធ្វើកាណូតឲ្យគេណាស់។
ក៖
ហើយគាត់ស៊ីឈ្នួលធ្វើកាណូតឲ្យគេទៅហើយគាត់បានមកឃើញអ្នកម្ដាយរបស់អ៊ុំទៅ។
ខ៖ អត់ទេគាត់មកស៊ីឈ្នួលគេនៅព្រែកលៀបគាត់ទៅរែកទឹកម្លូលឲ្យគេហោស។
ក៖ បាទ!
ខ៖ ចា៎!
ក៖ បាទ! ហើយអញ្ចឹងគាត់រែកទឹកម្លូលឲ្យហើយបានគាត់មកឃើញម្ដាយរបស់អ៊ុំស្រីទៅ។
ខ៖ ចា៎!
ក៖ បាទ! ហើយបានមកធ្វើការនិងទៅ។
អ៊ុំស្រី៖ ចា៎! ហើយគាត់បានធ្វើការនិងគាត់កាណូតទៅ។
ក៖ បាទ!
ហើយគាត់មកធ្វើកាណូតវិញ។ហើយអញ្ចឹងកាលនិងអ្នកម្ដាយអ៊ុំគាត់ធ្វើអីគេដែរអ៊ុំស្រី?
ខ៖ ហើយម្ដាយខ្ញុំគាត់ខាងលក់អំពៅលក់អីនិង។
ក៖ បាទ!ហើយគាត់អ្នកលក់អំពៅហើយដើរៗទៅគាត់ឃើញទៅ។
ខ៖ ចា៎!
ក៖ ហើយអញ្ចឹងលោកឪពុកគាត់ឃើញទៅហើយគាត់ចាប់អារម្មណ៍ទៅ។
ខ៖ ចា៎!
ក៖ បាទ! ស្នេហាតាមវេហានិងអ៊ុំស្រី។
ខ៖ ចា៎!
ក៖
ហើយអញ្ចឹងអ៊ុំមានចាំសាច់រឿងជាមួយម្ដាយឪពុកថាធ្លាប់ទៅណាជាមួយគ្នាហើយធ្លាប់អី ជាមួយគ្នាអញ្ចឹងហើយអ៊ុំមានចាំទេ?
ខ៖ ខ្ញុំជាមួយប៉ាខ្ញុំ។
ក៖ បាទ!
ខ៖ ខ្ញុំអត់សូវដឹងដែរនិងព្រោះអីខ្ញុំនៅតូចហើយខ្ញុំដឹងថាគាត់អត់ដែរទាសគ្នាផងនិង។
ក៖ បាទ! ហើយដូចថាអ៊ុំជាមួយពួកគាត់។
ខ៖ ខ្ញុំជាមួយគាត់មែន។
ក៖ បាទ!
ខ៖ អត់ដែរផងនិងខ្ញុំអត់សូវទៅជាមួយគាត់ទេច្រើនតែគាត់ទៅតែគាត់និងទៅណាស់។
ក៖ បាទ! ហើយអញ្ចឹងគាត់ទៅតែពីរនាក់ទៅរកស៊ីទៅ។
ខ៖ ចា៎!

កៈ ហើយអញ្ជឹងគាត់អត់ដែលនាំអ៊ុំទៅណាទៅណីទេអ៊ុំស្រី។
ខៈ អត់ទេ។
កៈ ហើយដូចទៅណាជាលក្ខណៈគ្រួសារទេអ៊ុំស្រី?
ខៈ អត់ដែរទេ។
កៈ បាទ! អត់ដែរទេ។ហើយអញ្ជឹងគាត់ដែរវាយអ៊ុំទេ។
ខៈ គាត់ធ្លាប់វាយតា។
កៈ បាទ! ហើយគាតធ្លាប់វាយអ៊ុំដែរហើយគាត់វាយរឿងអីអ៊ុំឬអ៊ុំខូចពេកអ៊ុំស្រី។
ខៈ ខ្ញុំអត់ខូចទេហើយខ្ញុំតាមគាត់និងហើយគាត់វាយតែម្តងនិង។
កៈ បាទ! ហើយអ៊ុំរឿងអីអ៊ុំស្រី?
ខៈ ខ្ញុំតាមគាត់ទៅដាក់លប់និង។
កៈ បាទ! ហើយតាមគាត់ទៅកន្លែងទឹកនិងអ៊ុំស្រី។
ខៈ ចាំ!
ហើយគាត់ថាអត់ឲ្យចុះទឹកហើយយើងរឹងចុះទឹកទៅហើយគាត់ត្រលប់មកវិញគាត់វាយខ្ញុំទៅ។
កៈ បាទ! ហើយមិនអ៊ុំថាអត់ខូចទេតែអ៊ុំរឹង។ហើយអញ្ជឹងបងគាត់មានដែរវាយទេ។
បងស្រីៈ គាត់វាយតា។
កៈ បាទ! ប្រហែលកូនពៅគាត់អត់សូវវាយទេបងស្រី។
បងស្រីៈ គាត់វាយដែរមិនអត់ទេ។
កៈ បាទ! គាត់វាយដែរ។
បងស្រីៈ គាត់វាយដែរតែតិចជាងបងៗហើយគាត់កើតមុនយើងអីអញ្ជឹងណាស់។
កៈ បាទ! ហើយអញ្ជឹងគាត់វាយបានប៉ុន្មានដងដែរបងស្រី?
បងស្រីៈ គាត់វាយជាងប្រាំប្រាំមួយដងដែរនិង។
កៈ បាទ! ហើយអញ្ជឹងវាយប្រាំប្រាំមួយដងដែរបងស្រី។
បងស្រីៈ ចាំ!
កៈ បាទ! ហើយគាត់វាយថាបងឯងខូចដែរអត់ទេ។
បងស្រីៈ អត់ទេ។ហើយខ្ញុំអត់ដឹងដែរកាលពីតូចខ្ញុំអត់ដឹងដែរនិង។
កៈ បាទ! ហើយមែនរឹងដូចគាត់ដែរទេ។
បងស្រីៈ អត់ទេខ្ញុំអត់រឹងដូចគាត់ទេ។
កៈ បាទ! ហើយអញ្ជឹងតាមចុះទឹកដែរទេបងស្រី។
បងស្រីៈ អត់ទេ។
កៈ
ហើយអញ្ជឹងអ៊ុំគាត់មានដែរប្រាប់ពីខ្សែជីវិតរបស់គាត់កាលគាត់នៅពីក្មេងហើយថាគាត់មានការលំបាកដែរបានជួបម្តាយរបស់អ៊ុំស្រីអញ្ជឹងណាស់។
ខៈ គាត់ប្រាប់ដែរកាលពីគាត់នៅស្រុកនិង។

ក៖ បាទ!
ខ៖ ហើយគាត់ថាដូចគាត់កំព្រាម៉ែឪអញ្ចឹងណាស់។
ក៖ បាទ!
ខ៖
ហើយគាត់ដើរស៊ីឈ្នួលគេតាមអ្នកជិតខាងនិងទៅតហូតមកហើយបានគាត់ធំទៅហើយគាត់បានមកស៊ីឈ្នួលគេនិងព្រៃលៀបនិងទៅណាស់។
ក៖ បាទ! ហើយគាត់បានពេញរូបពេញរាងបានគាត់មកស៊ីឈ្នួលគេ។
ខ៖ ចាំ!
ក៖
ហើយអញ្ចឹងគាត់ស៊ីឈ្នួលគេនិងគាត់ធ្វើស៊ីឈ្នួលនិងយូរហើយតាំងពីគាត់នៅក្មេងមកម្លេះ។
ខ៖ ចាំ! គាត់ស៊ីឈ្នួលគេនិងយូរហើយ។ហើយគាត់ថាតាំងពីតូចៗមក។
ក៖ បាទ! តាំងពីតូចៗមកអ៊ុំស្រី?
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងគាត់មានការជូរជត់ច្រើនណាស់អ៊ុំស្រី។
ខ៖ ចាំ! គាត់មានជូរជត់ច្រើនណាស់ប៉ុន្តែគាត់មិនអាចប្រាប់យើងណាស់។
ក៖ បាទ! ហើយអញ្ចឹងគាត់កាចទេអ៊ុំស្រី។
បងស្រី៖ ប៉ាខ្ញុំគាត់ស្លូតណាស់។
ក៖ បាទ! គាត់ស្លូតណាស់អ៊ុំស្រី។
ខ៖ ចាំ! គាត់ស្លូតណាស់។
ក៖ បាទ!
ខ៖ ម្តាយខ្ញុំគាត់កាច។
ក៖ បាទ! ហើយអញ្ចឹងអ្នកម្តាយគាត់វាយលោកឪពុកវិញ។
ខ៖ អត់ទេគាត់ស្រឡាញ់គ្នាណាស់ហើយគាត់អត់ដែរមានការប៉ះទង្គិតគ្នាទេ។
ក៖ បាទ! ហើយអញ្ចឹងគាត់អត់ដែរប៉ះទង្គិតគ្នាម៉ងអ៊ុំស្រី?
ខ៖ អត់សោះគាត់អត់ដែរទេ។
ក៖
បាទ!ហើយអញ្ចឹងគាត់ធ្វើឲ្យកូនៗមានសេចក្តីសុខហើយមានសុភមង្គលនៅក្នុងគ្រួសារអ៊ុំណោះ។
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងគាត់មានការស្រឡាញ់នៅក្នុងគ្រួសារ។
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងគាត់អត់ដែរនាំអ៊ុំទៅដើរលេងទេអ៊ុំស្រី?
ខ៖ អត់ទេគាត់អត់ដើរព្រោះអីគាត់គិតពីការងារគាតនិង។

ក៖ បាទ! ដូចថាគាត់គិតពីការងាររបស់គាត់ណោះអ៊ុំស្រី?
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងគាត់អត់មានពេលសម្រាក់ទេអ៊ុំស្រី?
ខ៖ គាត់អត់មានពេលសម្រាក់ទេ។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំមានចាំឈ្មោះជីដូនជីតាខាងឪពុកខាងម្ដាយរបស់អ៊ុំទេអ៊ុំស្រី?
ខ៖ ខាងប៉ាខ្ញុំម៉ែខ្ញុំ។
ក៖ បាទ!
ខ៖ ខាងឪពុកខ្ញុំស្គាល់។
ក៖ បាទ! ហើយអញ្ចឹងគាត់មានឈ្មោះអីដែរអ៊ុំស្រី?
ខ៖ កុងខាងឪពុកគាត់ឈ្មោះ ហួត។
ក៖ បាទ! គាត់មានឈ្មោះ ហួត។ហើយអញ្ចឹងម៉ាខាងឪពុក។
ខ៖ ហើយម្ដាយខាងឪពុកគាត់មានឈ្មោះ ហួយ។
ក៖ បាទ! គាត់មានឈ្មោះ ហួយ ។ហើយអញ្ចឹងខាងម្ដាយ ។
ខ៖ ខាងម្ដាយ សួន ។
ក៖ បាទ! ឈ្មោះសួន ហើយកុងគាត់ឈ្មោះអីដែរ?
បងស្រី៖ កុងសួន ហើយយាយ ឡៃ។
ក៖ យាយ ឡៃ។ហើយអញ្ចឹងកាលអ៊ុំនៅតូចគាត់នៅមានប្រជន្មប៉ុន្មានដែរ?
ខ៖ កាលខ្ញុំនៅតូចៗគាត់នៅទេហើយគាត់ទើបស្លាប់នៅជំនាន់អាពតនិងទេ។
ក៖ បាទ! ហើយដល់ពេលជំនាន់អាពតបានគាត់ស្លាប់។
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងកាលនិងគាត់មានប្រជន្មប៉ុន្មានដែរអ៊ុំស្រី?
ខ៖
តាខ្ញុំចាស់ដែរហើយខ្ញុំអត់ដឹងថាគាត់មានប្រជន្មប៉ុន្មានទេខ្ញុំអត់ដឹងដែរនិងគាត់ចាស់ច្រើន។
ក៖ បាទ!ចឹងលោកយាយវិញ?
ខ៖
បើយាយខ្ញុំគាត់លែងពីតាខ្ញុំគាត់ទៅយកប្ដីក្រោយទៀតក៏គាត់នៅក្មេងតែគាត់ស្លាប់ក្រោយ
តាខ្ញុំទេ។
ក៖ បាទ!ក្រោយលោកតា?
ខ៖ ចាំ!ប្ដីគាត់មុនទេ។
ក៖
បាទ!អរចឹងវិញចឹងតើគាត់មានបានប្រាប់អ៊ុំថាគាត់កើតនៅណាស្រុកកំណើតគាត់នៅខេត្ត
ណាដែលអ៊ុំ?
ខ៖ យាយខ្ញុំ។
ក៖ បាទ!

ខ៖ យាយខ្ញុំគាត់ស្រុកគាត់នៅនឹងម៉ង។
ក៖ ស្រុកគាត់នៅនឹងម៉ង?
ខ៖ ចាំ!នៅនឹងម៉ងតាខ្ញុំក៏គាត់នៅនឹងដែល។
ក៖ បាទ!អរចឹងអ្នកភូមិជាមួយគ្នា?
ខ៖ ចាំ!
ក៖ បាទ!ដល់ពេលចឹងឃើញគ្នាក៏ស្រលាញ់គ្នាទៅ?
ខ៖ ចាំ!
ក៖
ហើយអញ្ចឹងអ្នកគ្រួសារអ៊ុំទាំងនិងជាអ្នកនៅខេត្តកណ្តាលនិងទាំងអស់។ហើយចំណែកលោកឪពុករបស់អ៊ុំជាអ្នកខេត្តកំពង់ចាម។
ខ៖ ចាំ! មានតែឪពុកខ្ញុំទេគាត់ជាអ្នកខេត្តកំពង់ចាម។
ក៖ បាទ!
ហើយអញ្ចឹងអ៊ុំស្រីមានបងប្អូនជីដូនមួយហើយនិងជីទូមួយដែរបានរស់នៅក្រៅប្រទេសដូចនៅអាមេរិចហើយនិងកាណាដាមានអត់អ៊ុំស្រី?
ខ៖ អត់មានផងនិង។
ក៖ បាទ!
អត់មានទេ។ហើយអញ្ចឹងបច្ចុប្បន្ននិងអ៊ុំស្រីមានបងប្អូនក្មួយទៅបម្រើការងារនៅប្រទេសកូរ៉េទេហើយដូចប្រទេសថៃទេអ៊ុំស្រី?
ខ៖ ចាំ! អត់មានទេ។
ក៖ បាទ! ហើយអញ្ចឹងអត់មានទេអ៊ុំស្រី។
ខ៖ បើនៅប៉ៃលិនបានមាន។
បងស្រី៖ បងប្អូនខ្ញុំនៅប៉ៃលិនមាន។
ក៖ បាទ! នឹងនៅក្នុងប្រទេសនិងខ្ញុំចង់សួរថាអ្នកក្រៅប្រទេសអញ្ចឹងណាស់។
ខ៖ អត់មានទេ។
បងស្រី៖ អត់មានទេ។
ក៖
អត់មានទេ។ហើយអញ្ចឹងអ៊ុំស្រីហើយបើនិយាយពីស្វាមីរបស់អ៊ុំគាត់មានឈ្មោះអីដែរអ៊ុំស្រី
?
ខ៖ គាត់ឈ្មោះ ថុយ។
ក៖ បាទ! មានឈ្មោះ ថុយ។
ខ៖ ប្តីខ្ញុំ។
ក៖ បាទ!
ខ៖ គាត់ឈ្មោះ ថុយ។
ក៖ បាទ! ហើយអញ្ចឹងបងស្រីប្តីបងមានឈ្មោះអ្វីដែរបងស្រី?

បងស្រី៖ ហើយប្ដីខ្ញុំឈ្មោះ កក្កដា។
ក៖ បាទ!
ហើយអញ្ចឹងបងស្រីហើយនិងអ៊ុំស្រីគាត់រៀបការនៅនិងតាបងស្រីហើយនិងអ៊ុំស្រី?
បងស្រី៖ ចាំ!
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងពេលដែរអ៊ុំស្រីការនិងបានប៉ុន្មានឆ្នាំហើយ?
ខ៖ ខ្ញុំការពេលនិងជិតបានមួយ២០ឆ្នាំហើយ។
ក៖ បាទ! ជិតបាន២០ឆ្នាំហើយ។ហើយអញ្ចឹងការតាំងពីឆ្នាំណាដែរអ៊ុំស្រី?
ខ៖ ភ្លេចដែរនិង។
ក៖ បាទ! ភ្លេចដែរអ៊ុំស្រីហើយគ្រាន់តែដឹងថាការបាន២០ឆ្នាំ។
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងបងស្រីទើបតែការតាអី?
បងស្រី៖ ខ្ញុំតាំងពីខ្ញុំអាយុ១៩ឆ្នាំហើយអញ្ចឹងខ្ញុំការបាន១៨ឆ្នាំហើយ។
ក៖ បាទ! ការបាន១៨ឆ្នាំហើយបងស្រី។
បងស្រី៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងបងស្រីអាយុ១៨ឆ្នាំការ។
បងស្រី៖ អត់ទេខ្ញុំអាយុ១៩ឆ្នាំខ្ញុំការនិង។
ខ៖ វាទាល់អាយុ១៩បានវាការពេលនិង។
ក៖ បាទ! ហើយអញ្ចឹងប្ដីរបស់អ៊ុំគាត់នៅមានប្រជន្មហើយគាត់បានចែកឋានហើយ។
ខ៖ ចាំ! គាត់នៅមានប្រជន្មរស់ទេ។
ក៖ បាទ! ហើយគាត់ឥឡូវនិងគាត់នៅណាដែរអ៊ុំស្រី?
ខ៖ ឥឡូវគាត់នៅខាងវិហារសួគ៍។
ក៖ គាត់ទៅធ្វើការអ៊ុំស្រី។
ខ៖ ខ្ញុំលែងគ្នាយូរហើយ។
ក៖ ហើយអញ្ចឹងគាត់លែងគ្នាយូរហើយអ៊ុំស្រី?
ខ៖ ចាំ! ហើយខ្ញុំលែងតាំងពីកូនកើតមកបានបីខែ។
ក៖ បាទ! ហេតុអីអ៊ុំស្រីឬក៏នៅជាមួយគ្នាអត់ចុះសម្រុងមែនអ៊ុំស្រី?
ខ៖
អត់ចុះសម្រុងគ្នានិងដោយសារវាប្រទាញយើងឲ្យទៅនៅស្រុកវានិងហើយយើងអត់ទៅ។
ក៖ បាទ!
ហើយអញ្ចឹងគាត់ចង់ឲ្យអ៊ុំទៅនៅវិហារសួគ៍ហើយអ៊ុំអត់ចង់ទៅនៅវិហារសួគ៍ហើយអញ្ចឹងអ៊ុំដាច់គ្នាទៅ។
ខ៖ ចាំ!
ក៖ អត់ប្រកែកអីទេ។

ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងអ៊ុំស្រីបន្សល់ទុកកូនប៉ុន្មានអ៊ុំស្រី?
ខ៖ មួយនិង។
ក៖ បាទ! តែមួយនិងអ៊ុំស្រីហើយអញ្ចឹងស្រីកូនប្រុស។
ខ៖ ចាំ! កូនស្រី។
ក៖ បាទ! កូនស្រីហើយអញ្ចឹងគាត់មានឈ្មោះអីដែរអ៊ុំស្រី?
ខ៖ ឈ្មោះស្រី លក្ខ័ណ ។
ក៖ បាទ! គាត់មានឈ្មោះស្រីលក្ខ័ណ។
ខ៖ ចាំ!
ក៖ បាទ!
ហើយអញ្ចឹងអ៊ុំស្រីបើនិយាយពីអាពាហ៍ពិពាហ៍របស់អ៊ុំអញ្ចឹងថាលោកឪពុកអ្នកម្ដាយគាត់ជាអ្នកផ្សំផ្គុំឲ្យឬក៏អ៊ុំបានឃើញគ្នាហើយស្រឡាញ់គ្នាអ៊ុំស្រី?
ខ៖ អត់ទេម្ដាយឪពុកគាត់អ្នកផ្សំផ្គុំឲ្យនិង។
ក៖ បាទ!
ហើយអញ្ចឹងឪពុកម្ដាយគាត់អ្នកផ្សំផ្គុំឲ្យហើយអញ្ចឹងពេលដែរដាច់អាពតទៅហើយគាត់ឲ្យការម៉ងអ៊ុំស្រី?
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងអ៊ុំដែរស្គាល់ហើយធ្លាប់ជួបមុខគាត់ពីមុខមកទេអ៊ុំស្រី។
ខ៖ គាត់អាសារមកដែរតា។
ក៖ អត់ទេអ៊ុំមុនអ៊ុំពេលរៀបការនិងអ៊ុំមានដែរជួបមុខគាត់ដែរទេ?
ខ៖ ខ្ញុំអត់ដែរឃើញហើយអត់ដែរដឹងផងនិង។
ក៖ បាទ! អត់ដែរឃើញទេ។
ខ៖ ចាំ! អត់ដែរឃើញគ្នាផងនិង។
ក៖ អត់សោះម៉ងអ៊ុំស្រី?
ខ៖ អត់ដែរ។
ក៖ បាទ! ហើយអញ្ចឹងឪពុកម្ដាយគាត់ផ្សំផ្គុំឲ្យការម៉ងទៅ។
ខ៖ ចាំ!
កាលនិងឪពុកវាឪពុកខាងប្ដីខ្ញុំនិងគាត់មកធ្វើការនៅនិងគាត់ប្រកាន់ខ្ញុំទុកឲ្យកូនគាត់។
ក៖ បាទ! ហើយអញ្ចឹងគាត់បានសម្លឹងមើលហើយទុកឲ្យកូនគាត់ទៅ។
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងអ៊ុំមានចាំថាគាត់ឲ្យជំនួនអ៊ុំប៉ុន្មានទេ?
ខ៖ ហើយបើការគេជូន។
ក៖ បាទ!
ខ៖ ៣០០០លុយខ្មែរយើងនិង។

ក៖ ៣០០០រៀលកាលនិងថ្លៃណាស់។
ខ៖ ចាំ!
៣០០០រៀលកាលនិងថ្លៃ៣០០០ហើយអង្ករមួយប៉ាវយើងសាយយើងនិងមួយប៉ាវអង្ករតំណាបយើងនិងមួយប៉ាវ។
ក៖ បាទ! ច្រើនដែរអ៊ុំស្រី។
ខ៖ ចាំ! មានតែប៉ុណ្ណឹង។
ក៖ ហើយអញ្ជឹងកាលនិងថ្លៃដែរហើយអញ្ជឹងកាលនិងអ៊ុំស្រីស្អាតដែរបានថ្លៃ។
ខ៖ ហោសមើលរូបថតម៉ាអែម។
ក៖ បាទ! រី ម៉ាអែមហើយអញ្ជឹងចេះម៉ាអែនទៀត។
ខ៖ ចាំ! ហើយពេលចាស់ខ្លួនទៅហើយ។
ក៖ ចេះតែតាមវ៉ៃយទៅណោះ។
ខ៖ ចាំ! ចេះតែតាមវ៉ៃយទៅ។
ក៖ បាទ! ហើយអញ្ជឹងទៅចាស់តាមវ៉ៃយទៅ។
ខ៖ ហើយយើងទៅធ្វើការកណ្ដាលថ្ងៃអីអញ្ជឹងទៅខូចសម្រាស់អស់ទៅ។
ក៖ បាទ! ហើយអញ្ជឹងអ៊ុំស្រីបានច្រើនតែអ្នកខ្លះអត់បាន១៥០០ផងកាលនិង។
ខ៖ ចាំ!
ក៖ ហើយអញ្ជឹងអ៊ុំស្រីកាលនិងពេលដែរអ៊ុំបានជួបគ្នានិងអ៊ុំធ្វើការឬអ៊ុំនៅរៀនពេលនិង?
ខ៖ ខ្ញុំធ្វើការតា។
ក៖ បាទ! ហើយអញ្ជឹងអ៊ុំធ្វើការអីគេដែរអ៊ុំស្រី?
អ៊ុំស្រី៖ ខ្ញុំធ្វើឈូកហើយធ្វើត្បាញក្រមាត្បាញអីនិង។
ក៖ ហើយអញ្ជឹងបានគេចូលចិត្តអ៊ុំស្រី។ហើយអញ្ជឹងអ៊ុំចេះត្បាញក្រមាអីទៅ។
ខ៖ ចាំ! ខ្ញុំចេះត្បាញក្រមាត្បាញមុងអីអញ្ជឹងទៅ។
ក៖ បាទ! ហើយអញ្ជឹងអ៊ុំចេះច្រើនអ៊ុំស្រី?
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ជឹងអ៊ុំចេះតាមឪពុកម្ដាយអញ្ជឹងអ៊ុំស្រី។
ខ៖ ចាំ! ខ្ញុំចេះតាម
ឪពុកម្ដាយខ្ញុំនិង។ព្រោះអីគាត់ចេះឲ្យខ្ញុំចេះហើយឪពុកម្ដាយខ្ញុំនិងគាត់បង្ហាត់និង។
ក៖ បាទ! ហើយអញ្ជឹងអ្នកម្ដាយរបស់អ៊ុំគាត់អ្នកចេះ។
ខ៖ ចាំ! គាត់អ្នកចេះអញ្ជឹងដែរនិង។
ក៖ បាទ! ហើយអញ្ជឹងអ៊ុំបន្តវេនពីគាត់ទៅ។
ខ៖ ចាំ! ខ្ញុំក៏បានបន្តវេនពីគាត់ទៅ។
ក៖ បាទ! ហើយអញ្ជឹងបានអ៊ុំបានបន្តវេនឲ្យកូនអ៊ុំទៀត។
ខ៖ ចាំ! នឹងហើយព្រោះអីភ្នែកខ្ញុំមើលអត់ឃើញ។
ក៖ បាទ!ព្រោះអីអំបោះតូចពេក។

ខ៖ ចាំ! អំបោះតូចពេក។
ក៖ បាទ!
ហើយអញ្ចឹងបើនិយាយទៅអ៊ុំអត់បានជួបជាស្វាមីរបស់អ៊ុំទេហើយឪពុកម្ដាយគាត់អ្នកផ្សំផ្គុំឲ្យហើយដល់ពេលរៀបការក៏ការទៅអ៊ុំស្រី។
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងពេលដែលបានរៀបការនិងបានប៉ុន្មានតុដែរ?
ខ៖ ពេលខ្ញុំរៀបការនិងខ្ញុំរៀបបាន១៨តុ។
ក៖ បាទ! ហើយអញ្ចឹងច្រើនផងអ៊ុំស្រី?
ខ៖ ចាំ! កាលនិង១៨តុហើយគេយកពីយើងនិង៣តុ។
ក៖ បាទ! គេចែក៣តុទៀត។
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងនៅសល់១៥តុលើអ៊ុំទាំងស្រុង។
ខ៖ ចាំ!
ក៖ បាទ! ហើយកាលនិងចំណងដៃបានច្រើន។
ខ៖ ចាំ! កាលនិងមិនសូវច្រើនទេកាលនិងគេតិចតួចហើយចងរបស់និង។
ក៖ បាទ! ហើយអញ្ចឹងកាលនិងគេចងអីគេដែរអ៊ុំស្រី?
ខ៖ ហើយកាលនិងចងត្រឹម៣ពាន់ទៅ៤ពាន់អីនិង។
ក៖ បាទ!ហើយអញ្ចឹងអត់ចង់អង្ករចងមាន់ទេអ៊ុំស្រី។
ខ៖ អត់ទេកាលណុងហើយអត់មានចងមាន់ចងអង្ករអត់ទេ។
ក៖ បាទ! ហើយអញ្ចឹងនិយាយពីភាសាខ្មែរនិងវិញអ៊ុំមានចេះសរសេរហើយចេះអានទេ។
ខ៖ អត់ចេះទាំងអស់និងម៉ងហើយងងឹតឆឹងម៉ងនិង។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំមានបានរៀនទេ?
ខ៖ ចាំ!កាលនិងខ្ញុំបានរៀនដែរតែរៀនបានមួយថ្ងៃហើយខ្ញុំខាន់១០ថ្ងៃ។
ក៖ បាទ! ហេតុអីដែរអ៊ុំស្រី?ហើយមិចបានអ៊ុំរៀន១ថ្ងៃខាន់១០ថ្ងៃ។
ខ៖ ចាំ! ព្រោះអីបងប្អូនខ្ញុំ១១នាក់។
ក៖ ហើយអញ្ចឹងបងប្អូនអ៊ុំ១១នាក់ហើយអញ្ចឹងអ៊ុំថា៥នាក់។
ខ៖ អត់ទេ។
បងស្រី៖ ដូចគាត់ទ្បូតផងហើយងាប់ផងអញ្ចឹងណាស់។
ខ៖ ចាំ!
ដូចគាត់ទ្បូតផងហើយងាប់ផងអញ្ចឹងណាស់ហើយខ្ញុំមើលថែទាំឪពុកម្ដាយពេលដែរគាត់នៅកូនខ្ចីអញ្ចឹងណាស់។
ក៖ បាទ!
ខ៖ ហើយអញ្ចឹងអត់បានទៅរៀនព្រោះយើងទៅរៀនមួយថ្ងៃហើយខាន់១០ថ្ងៃនិងណាស់។
ក៖ បាទ!

ខ៖ ហើយយើងមើលប្អូនហើយម្តាយទៅរកស៊ីអត់មានអ្នកណាមើលផ្ទះអញ្ចឹងណាស់។
ក៖ បាទ!
ខ៖ ហើយខ្ញុំនៅមើលប្អូន។
ក៖ ហើយអញ្ចឹងអ៊ុំអត់បានទៅរៀនទេ។
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងពេលដែរចប់អាពតនិងអ៊ុំមានបានទៅរៀនអក្សរកម្មទេអ៊ុំស្រី?
ខ៖ ខ្ញុំបានទៅរៀនដែរប៉ុន្តែអត់ចេះ។
ក៖ បាទ! អត់ចេះ។
ខ៖ ខ្ញុំរៀនអត់ចូរ។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំរៀនអត់ចូលព្រោះអីអ៊ុំស្រីមានអាយុច្រើនជាងគេ។
ខ៖ ចាំ! ព្រោះអីខ្ញុំមានអាយុច្រើនហើយនៅមើលប្អូនទៀត។
ក៖ បាទ! ហើយអញ្ចឹងរៀនអត់ចូលទេ។
ខ៖ ចាំ! ហើយអញ្ចឹងខ្ញុំរៀនអត់ចូលអញ្ចឹងទៅ។
ក៖ បាទ!
ហើយអញ្ចឹងក្រៅពីភាសាខ្មែរដូចជាភាសាថៃហើយនិងភាសាវៀតណាមវិញអ៊ុំមានចេះទេ?
ខ៖ អត់ចេះទេងងឹតសូន្យម៉ងនិង។
ក៖ អត់ចេះមួយមាត់ពីរមាត់អីអត់ចេះទេ។
ខ៖ អត់ចេះទេ។
ក៖ បាទ!
ខ៖ ចេះតែ OK មួយមុខនិង។
ក៖ បាទ! ចេះតែ OK មួយមុខអ៊ុំស្រី?
ខ៖ ចាំ!
ក៖ បាទ!ហើយអញ្ចឹង  OK និងមានន័យថាមិចអត់អ៊ុំស្រី?
ខ៖ អត់ដឹងថាមិចផងនិង។
ក៖ អត់ដឹងថាមិចលឺគេថា OK ថាតាមគេទៅអ៊ុំស្រី?
ខ៖ ចាំ! លឺថាគេហៅអញ្ចឹងថាតាមគេទៅ។
ក៖ បាទ! ម៉ាយ៉ាងដែរ។ហើយអញ្ចឹងអ៊ុំពេលនិងអ៊ុំបានរៀនថ្នាក់ទីប៉ុន្មានដែរ?
ខ៖ ចាំ! ពេលនិងខ្ញុំបានរៀនថ្នាក់ទី១និង។
ក៖ បាទ!
ហើយអញ្ចឹងអ៊ុំបានរៀនត្រឹមថ្នាក់ទី១និងអ៊ុំស្រី?ហើយអញ្ចឹងមានចាំឈ្មោះសាលាអ៊ុំទេ?
ខ៖ ចាំ! ចាំឈ្មោះខ្ញុំរៀននៅវត្តនិងហើយរៀនសាលាលោកនិង។
ក៖ រៀនសាលាលោក។ហើយអញ្ចឹងវត្តអីគេដែរអ៊ុំស្រី?
ខ៖ វត្តក្បាលកោះយើងនិង។
ក៖ វត្តក្បាលកោះយើងនិង។

ខ៖ ចាំ!
ក៖ បាទ! វត្តក្បាលកោះនិងហើយអញ្ចឹងរៀនជាមួយលោកជាមួយអីទៅអ៊ុំស្រី?
ខ៖ ចាំ! ពេលនិងលោកគាត់អ្នកបង្រៀននិង។
ក៖ បាទ!
ខ៖ ហើយកាលនិងលោកគាត់ធ្វើគ្រូ។
ក៖ បាទ! ហើយអញ្ចឹងលោកគាត់ធ្វើគ្រូ។
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងលោកនិងគាត់កាចទេ?
ខ៖ គាត់កាចដៃរនិងវត្តឆ្នាចបែកខ្នងដៃរនិង។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំមានដៃរលោកគ្រូវាយអត់អ៊ុំស្រី?
ខ៖ អត់ទេ។
ក៖ បាទ! ហើយអត់ដៃរគ្រូវាយទេ។
ខ៖ ចាំ!
ក៖ អត់ដៃរវាយសោះម៉ង។
ខ៖ អត់។
ក៖ ហើយអញ្ចឹងអ៊ុំរៀនពូកែហើយអញ្ចឹង។
ខ៖ ចាំ! ហើយខ្ញុំអត់រៀនពូកែទេហើយខ្ញុំអត់មានប្រឆ្លេប្រឆ្លោះឲ្យគ្រូវាយទេ។
ក៖ បាទ!
ហើយអញ្ចឹងអ៊ុំកាលដៃរអ៊ុំបាននៅរៀនហើយពេលនៅក្នុងភូមិអ៊ុំមានមិត្តភក្ដិប៉ុន្មាននាក់ដៃរអ៊ុំស្រី?
ខ៖ ខ្ញុំអត់ដៃរមានមិត្តភក្ដិទេ។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំអត់ដៃរមានមិត្តភក្ដិទេអ៊ុំស្រី?ហើយអញ្ចឹងចេញពីរៀនចូលផ្ទះ។
ខ៖ ចាំ! ចេញពីរៀនចូលផ្ទះ។
ក៖ បាទ! ហើយអញ្ចឹងអត់ដៃរដើរទៅណាទេអ៊ុំស្រី?
ខ៖ អត់ដៃរផងនិង។ព្រោះអីម្ដាយខ្ញុំកាចហ៊ានតែដើរជេបីយប់បីថ្ងៃនិងឥឡូវនិងហើយ។
ក៖ បាទ! ហើយអញ្ចឹងអ្នកម្ដាយគាត់កាចអ៊ុំស្រី?
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងគាត់ជេអញ្ចឹងម៉ង។
ខ៖ ចាំ!គាត់ជេឆ្អើលឥឡូវនិងហើយ។
ក៖ បាទ! ហើយអញ្ចឹងចេញពីរៀនមកត្បាញក្រមានិងទៅអ៊ុំស្រី?
ខ៖ ចាំ! ខ្ញុំត្បាញក្រមានិងហើយខ្ញុំធ្វើឈ្នូក។
ក៖ បាទ! ហើយអញ្ចឹងធ្វើឈ្នូកទៅ។
ខ៖ ហើយខ្ញុំស៊ីឈ្នួលកាចឈ្នូកឲ្យគេ។
ក៖ ហើយអញ្ចឹងអ៊ុំធ្លាប់ស៊ីឈ្នួលគេដៃរអ៊ុំស្រី?

ខ៖
ខ្ញុំធ្លាប់ស៊ីឈ្នួលតាខ្ញុំស៊ីឈ្នួលគេកាចឈូកគេនិងហើយដូចវាយកឲ្យខ្ញុំមួយប៉ាវនិងខ្ញុំកាប់ទៅណាស់ហើយយើងកាប់ឲ្យគេទៅហើយគេយកសាច់ទៅហើយយើងយកឈ្នួលមក។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំមានធ្លាប់ស៊ីឈ្នួលធ្វើស្រែធ្វើចំការទេអ៊ុំស្រី?
ខ៖ អត់ផងនិង។
ក៖ អត់ទេ។
អ៊ុំស្រី៖ នៅនិងគេអត់ធ្វើស្រែទេហើយអញ្ចឹងអត់មានទេ។
ក៖ បាទ! ហើយអញ្ចឹងអត់មានទេ។
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងធ្វើតែឈូកឲ្យគេទៅ។
ខ៖ ចាំ! ខ្ញុំធ្វើតែឈូកឲ្យគេទៅ។ហើយត្បាញក្រមាឲ្យគេទៅណាស់។
ក៖ បាទ! ហើយអញ្ចឹងកាលនិងបានប៉ុន្មានដែរអ៊ុំស្រី?
ខ៖ កាលនិងបាន១០ទៅ១៥រៀលនិង។
ក៖ បាទ! កាលនិងបាន១៥រៀលអ៊ុំស្រី?
ខ៖ ចាំ!
ក៖ ច្រើនដែរតា។
ខ៖ ចាំ!
ក៖ បាទ! ហើយ១៥រៀលជំនាន់និងថ្លៃ។
ខ៖ ចាំ! ថ្លៃ។
ក៖ បាទ! ប្រហែលស្មើ១៥០ដុល្លាឥឡូវនិង។
ខ៖ ចាំ!
ក៖
ហើយអញ្ចឹងកាលពីតូចរហូតមកដល់ធំហើយមកដល់ឥឡូវនិងអ៊ុំមានការផ្លាស់ប្តូរអ្វីខ្លះទេដូចថាអ៊ុំមានការសប្បាយហើយមានការជួបការលំបាកអញ្ចឹងណាស់។
ខ៖
ហើយបើនិយាយរឿងសប្បាយនិងកំរបានសប្បាយណាស់ហើយព្រោះវាមិនសូវបានសប្បាយព្រោះអីមកដឹងពីការងារផ្ទះរហូតហើយអត់ដែរបានដើរលេងឆ្ងាយនិងគេបានម្តងទេ។
ក៖ បាទ! ហើយអញ្ចឹងពេលដែរអ៊ុំមានគ្រួសារនិងអ៊ុំមានការសប្បាយអីខ្លះទេ?
ខ៖ បើនិយាយពីការសប្បាយនិងពេលមានគ្រួសារនិងរឹតជំពៅទ្រង់ជាងនៅពីក្មេងទៀត។
ក៖ បាទ!
ខ៖ ព្រោះអីប្តីយើងនិងពិបាក។
ក៖ បាទ! ពិបាកអីគេដែរអ៊ុំស្រី?
ខ៖ ហើយថាពិបាកព្រោះគេរអ្វូរទាំច្រើនណាស់។
ក៖ បាទ! រអ្វូអត់លុយមែនអ៊ុំស្រី?

ខ៖ ហើយដូចថារអូរទាំថាលុយវាអត់បានគ្រប់គ្រាន់អញ្ចឹងណាស់។
ក៖ ហើយមែនគាត់ទៅមានស្រីទេ។
ខ៖ អត់ទេ។
ក៖ ហើយអញ្ចឹងពេលដែរគាត់បែកពីអ៊ុំអញ្ចឹងគាត់មានគ្រួសារមួយទៀតដែរអ៊ុំស្រី?
ខ៖ មាន។
ក៖ ហើយអញ្ចឹងគាត់មានស្រីហើយអញ្ចឹង?
ខ៖ អត់ទេបែកពីយើងទៅបានមាន។
ក៖ បាទ!ហើយអញ្ចឹងអ៊ុំអត់មានពេលសប្បាយអីបន្តិចសោះម៉ងអ៊ុំស្រី?
ខ៖ ចាំ! អត់មានទេ។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំជួបឧបសគ្គរហូត។
ខ៖ ជួបឧបសគ្គរហូត។
ក៖ បាទ!
ខ៖ ហើយឥឡូវនិងមានឧបសគ្គរហូតដែរ។
ក៖ បាទ! មានឧបសគ្គណាដែរអ៊ុំស្រី?
ខ៖ ហើយអត់ដែរមានរីករាយអត់ដែរបានទៅណា។
ក៖ បាទ !ហើយអញ្ចឹងឥឡូវនិងអ៊ុំមានកូនចៅប៉ុន្មានដែរ?
ខ៖ ខ្ញុំមានចៅតែមួយ។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំមានចៅតែមួយទេហើយកុំឲ្យអផ្សុកអ៊ុំណោះ។
ខ៖ ចាំ!
ក៖ បាទ! ហើយអញ្ចឹងបើនិយាយពីមុខម្ហូបអ៊ុំចូលចិត្តមុខម្ហូបអីជាងគេ?
ខ៖ ហើយមុខម្ហូបខ្ញុំបើនិយាយពីមុខម្ហូបសាច់ជ្រូកសាច់មាន់អត់ចូលចិត្តសោះ។
ក៖ បាទ!
ហើយអញ្ចឹងសាច់ជ្រូកសាច់មាន់អត់ចូលចិត្តទេហើយបើដូចសម្លម្ជូលគ្រឿងហើយសម្លឹក
ប្រហើរអីអ៊ុំចូលចិត្ត។
ខ៖ ចាំ! ហើយនិងបាន។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំចូលចិត្ត។
ខ៖ ចាំ! ខ្ញុំនិងចូលចិត្តដែរនិង។ហើយនិងញ៉ោមខ្ទៅអីនិងខ្ញុំចូលចិត្ត។
ក៖ បាទ! ហើយអញ្ចឹងម្ហូបប្រចាំត្រកូលរបស់អ៊ុំស្រី?
ខ៖ បើប្រចាំត្រកូលនិងមានតែញ៉ោមខ្ទៅទេ។
ក៖ បាទ! មានតែញ៉ោមខ្ទៅហើយអញ្ចឹងញ៉ោមខ្ទៅនិងឆ្ងាញ់ណាស់អ៊ុំស្រី?
ខ៖ ចាំ!
ក៖ បាទ! ហើយនិងប្រចាំត្រកូលម៉ងអ៊ុំស្រី?
ខ៖ ចាំ! និងខ្ញុំចូលចិត្ត។ហើយបើសាច់ជ្រូកសាច់មាន់អីនិងអត់ចូលចិត្តទេ។
ក៖ បាទ! ហើយនិងអត់ចូលចិត្តទេ។ហើយញុំានិងហើយអ៊ុំរបស់ធម្មជាតិអ៊ុំស្រី?

ខ៖ ចាំ!ហើយនិងបានញុាំមួយមាត់និងឆ្ងាញ់ណាស់។
ក៖ បាទ! ហើយម្ហូបអីផ្សេងអត់ចូលចិត្តទេ។
ខ៖ អត់ចូលចិត្តទេសួរកូននៅនិង។
ក៖ បាទ!
ហើយអញ្ចឹងបើល្បែងប្រជាប្រិយដូចជាចោលឈូកបោះអង្គញហើយនិងលាក់កន្សែងទាញព្រ័ត្តអីអុំមានចូលចិត្តទេ?ហើយពេលដែរអុំនៅពីក្មេងហើយនៅពីក្រមុំអុំមានចូលចិត្តទេ?
ខ៖ ចាំ!
ហើយខ្ញុំចូលចិត្តដែរតែម៉ែគាត់ឃោតឃាំងមិនឲ្យទៅលេងនិងហើយអត់ឲ្យទៅប្រផ្លែប្រផ្លោះអីណាទេ។
ក៖ បាទ! គាត់អត់ឲ្យទៅលេងសោះម៉ងអុំស្រី?
ខ៖ អត់ទេ។
ក៖ ហើយអញ្ចឹងចូលឆ្នាំខ្មែរអត់ដែរ?
ខ៖ អត់ទេ។ហើយគ្រាន់តែវត្តនិងទាល់តែគាត់ទៅបានបានទៅ។
ក៖  បាទ!
ខ៖ ហើយបើគាត់អត់បានទៅគឺអត់ហើយ។
ក៖ បាទ! ហើយគាត់ឃោតឃាំងណាស់អុំស្រីណោះ។
ខ៖ ចាំ!
ក៖ ហើយអញ្ចឹងម្ដាយគាត់បារម្ភនិងកូនអញ្ចឹងល្អ។
ខ៖ គាត់បារម្ភរហូតនិង។
ក៖ បាទ! ហើយអញ្ចឹងអុំបើនិយាយការរាំហើយនិងការច្រៀងនិងវិញអុំចូលចិត្តទេ?
ខ៖ ចូលចិត្តុំ
ក៖ បាទ!ហើយអញ្ចឹងការរាំហើយនិងច្រៀងនិងចូលចិត្ត។
ខ៖ ចាំ! ហើយខ្ញុំបានតែកន្ទុរគេនិងនិងបានបានរាំណាស់។
ក៖ បាទ!
អុំស្រី៖ ហើយបើអត់បានទៅកន្ទុរគេទេអត់បានទេ។
ក៖ បាទ! ហើយអញ្ចឹងអុំស្រីចូលចិត្តប៉ុន្មានបទដែរ។
ខ៖ បទអីក៏ទៅចេះដែរតែស្លោទេអត់ចេះ។
ក៖ បាទ! ហើយអញ្ចឹងបទសម័យឥឡូវចេះអត់អុំស្រី?
ខ៖ អរបទសម័យឥឡូវចេះដែរតែចេះតិចៗ។
ក៖ បាទ! ហើយបើបទញ្ញែកឥឡូវនិងអុំអាចរាំបានទេ។
ខ៖ ចាំ! បាន។
ក៖ បាទ! ហើយបទពីដើមក៏បានហើយសម័យក៏បានដែរ។
ខ៖ ចាំ!
ក៖ បាទ!ទាំងអស់អត់ឲ្យចាញ់ក្មេងជំនាន់ក្រោយនិងទេអុំស្រី?

ខ៖ អត់ឲ្យចាញ់ទេហើយដូចញ្ញីកែងជើងអីនេះ។
ក៖ បាទ! ចេះញ្ញីកែងជើងទៀតហើយអញ្ជឹងអ៊ុំស្រីចេះច្រៀងអត់។
ខ៖ អត់ចេះទេ។
ក៖ អត់ចេះទេចេះតែរាំ។
ខ៖ ចេះតែរាំ។
ក៖ ហើយអញ្ជឹងបទមួយណាដែរអ៊ុំចូលចិត្តរាំជាងគេ។
ខ៖ ថាចូលចិត្តទាំងអស់និង។
ក៖ បាទ!ហើយអញ្ជឹងចូលចិត្តទាំងអស់និងឲ្យតែបទញ្ញែកចូលចិត្តទាំងអស់។
ខ៖ ឲ្យបទញ្ញែក។
បងស្រី៖ គាត់ចូលចិត្តទាំងអស់ឲ្យតែញ្ញែក។
ក៖ បាទ! ព្រោះអីអ៊ុំគាត់មានអាយុវ័យគាត់ប៉ុន្មានហើយពេលបុណ្យនៅវត្តអីអ៊ុំទៅរាំអត់។
ខ៖ អត់ទេរាងខ្មាស់តិច។
ក៖ រាងខ្មាស់ហើយអញ្ជឹងបើរាំចាស់ៗគ្នាឯងទៅរាំអត់។
ខ៖ ហើយបើថាចាស់វ័យប៉ុណ្ណឹងទៅអីចូលរាំដែរនិង។
ក៖ ហើយពេលមានបុណ្យភូមិអីទៅអត់។
ខ៖ ទៅ។
ក៖ ទៅរាំហើយដូចញ្ញីកែងជើងអីអត់ចោលទេអ៊ុំស្រី?
ខ៖ អត់ចោលទេ។ហើយនិងបទខោរហែក។
ក៖ អរខោរហែកទៀត។
បងស្រី៖ ហើយដូចបទមាន់ស្រែអីក៏គាត់ចេះដែរ។
ក៖ បាទ! ហើយមាន់ស្រែចេះទៀត។ហើយអញ្ជឹងបងស្រីចូលចិត្តអត់?
បងស្រី៖ សួរខ្ញុំ។
ខ៖ មិនបាច់សួរទេបើច្រៀងនិងអ៊ែម។
ក៖ បាទ! ហើយអញ្ជឹងបទអីបងស្រីចេះ។
បងស្រី៖ ខ្ញុំចូលចិត្តទាំងអស់និង។
ក៖ បាទ!ៗហើយអញ្ជឹងតារាណាដែរនៅក្នុងដួងចិត្តរបស់បងស្រី?
បងស្រី៖ តារានៅក្នុងដួងចិត្តរបស់ខ្ញុំជាងគេមាស សុខសោភានិងខេម។
ក៖ បាទ! ហើយបងស្រីចូលចិត្តខេមទៀត។
បងស្រី៖ ខ្ញុំចូលចិត្តណាស់។
ក៖ បាទ! ហើយអញ្ជឹងបងស្រីចូលចិត្តប៉ុន្មានបទដែរ?
បងស្រី៖ ចា៎!
ក៖ បាទ! ហើយអញ្ជឹងបងស្រីចូលចិត្តប៉ុន្មានបទដែរ?
បងស្រី៖ ហើយខ្ញុំចូលចិត្តមាស សុខសោភាច្រើនបទម៉ងនិង។
ក៖ បាទ! ហើយអញ្ជឹងបងស្រីចេះច្រើនម៉ងនិង។

បងស្រី៖ ចាំ!
ក៖ ហើយបទឥឡូវនិងចូលចិត្តដែរ?
បងស្រី៖ ចាំ!
ក៖ ហើយដូចបទមេឃភ្លៀងហើយ។
បងស្រី៖ អរមេឃភ្លៀងហើយនិងចូលចិត្តណាស់។
ក៖ បាទ!
បងស្រី៖ កុំនិយាយ។
ក៖ បាទ!ចេះទាំងអស់។
បងស្រី៖ ចាំ!
ក៖ បាទ! ហើយថាមាស សុខសោភា។
បងស្រី៖ ឲ្យតែមាស សុខសោភា។
ក៖ បាទ!
បងស្រី៖ តារានៅក្នុងដួងចិត្តរបស់ខ្ញុំហើយនិង។
ក៖ បាទ!ហើយចុះខេមរិញបងចូលចិត្តប៉ុន្មានបទដែរ?
បងស្រី៖ ខ្ញុំចូលចិត្តច្រើនម៉ងនិង។
ក៖ ច្រើនទាំងអស់ម៉ងឲ្យតែបទចេញថ្មីនិង។
បងស្រី៖ ឲ្យតែរ៉ុលគាត់ខ្ញុំចូលចិត្ត។
ក៖ ហើយទឹកភ្នែកក្មេងពាអីនិងចេះទេ?
បងស្រី៖ នឹង។
ក៖ ចេះដែរ។
បងស្រី៖ ចាំ!
ក៖ បាទ!
បងស្រី៖ ប៉ុន្តែខ្ញុំអត់ច្រៀងព្រោះអីបទប្រុស។
ក៖ ហើយអញ្ចឹងបងស្រីអាចដាក់ THE VIOCEបងស្រី។
បងស្រី៖ ហេសៗ។
ក៖ បាទ!
បងស្រី៖ នឹងទុកប្រគល់ឲ្យកូនចុះ។
ក៖ បាទ!
បងស្រី៖ នោះកូនប្រុសខ្ញុំ។
ក៖ បាទ! ហើយអញ្ចឹងបងមានកូនប៉ុន្មាននាក់?
បងស្រី៖ ខ្ញុំមានកូនបីនាក់។
ក៖ បាទ! បីនាក់ហើយកូនទីមួយមានឈ្មោះអីគេដែរបងស្រី?
បងស្រី៖ កូនទីមួយមានឈ្មោះ ស្រីតី។
ក៖ បាទ! ហើយនិងទីមួយនឹងមែនបងស្រី?

បងស្រី៖ ចាំ!
ក៖ ហើយអញ្ចឹងទីពីរបងស្រី?
បងស្រី៖ កូនទីពីរមានឈ្មោះថាវ៉ាន់នុត ។
ក៖ បាទ! ហើយកូនទៅបី។
បងស្រី៖ នោះវ៉ាឌី។
ក៖ បាទ!
បងស្រី៖ ហើយនេះប្ដីខ្ញុំ។
ក៖ បាទ! ហើយនិងប្ដីបងស្រី។
បងស្រី៖ ចាំ!
ក៖ បាទ!ហើយអញ្ចឹងប្រុសពីរស្រីមួយ។
បងស្រី៖ អត់ទេស្រីពីរប្រុសមួយ។
ក៖ បាទ!
ហើយអញ្ចឹងប្រុសមួយស្រីពីរ។ហើយអញ្ចឹងអ៊ុំបើនិយាយពីអ្នកក្នុងក្រុមគ្រួសាររបស់អ៊ុំដូចបងប្អូនជីដូនមួយហើយមានអ្នកណាដែរគេចេះលេងឧបករណ៍តន្ត្រីដូចជាស្គរ រណាត ហ្គីតាហើយនិងព្យាណូទេអ៊ុំស្រី?
ខ៖ អត់មានទេតែមានចេះរាំរបាំមួយ។
ក៖ បាទ! ចេះរាំរបាំមួយ។
បងស្រី៖ កូនខ្ញុំពីរនាក់និង។
ក៖ បាទ! ពីរនាក់និងគាត់ចេះរាំរបាំ។
បងស្រី៖ ចាំ!
ក៖ ហើយមិញបងថាពីរនាក់។
បងស្រី៖ កូនខ្ញុំពីរនាក់និងមិញនិងប្រុសមិញនិង។
ក៖ បាទ! ប្រុសមិញនិងចេះរាំ។
បងស្រី៖ ចាំ! ទាំងពីរនិង។
ក៖ ចេះរាំរបាំអីគេ?
បងស្រី៖ របាំគ្រប់ឲ្យខ្មែរយើងនិង។
ក៖ ហើយរបាំទ្រុតនិងគាត់មានចេះទេ?
បងស្រី៖ ទ្រុតអត់ទាន់ទេគេរៀនអត់ទាន់ទេ។
ក៖ បាទ! រៀននៅណាដែរ?
បងស្រី៖ កូនខ្ញុំចេះរាំរបាំបាច់ផ្កាកូនស្រីខ្ញុំនិង។
ក៖ គាត់រៀនទៅវិចិត្រសិល្បះគាត់រៀននៅណាផ្សេង។
បងស្រី៖ អត់ទេកូនខ្ញុំរៀននៅសាលាបារាំងនិង។
ក៖ បាទ! ហើយអញ្ចឹងគាត់ចេះរាំរបាំ។
បងស្រី៖ ចាំ!

កៈ
ហើយអញ្ជឹងបើនិយាយពីផ្ទះដែរអ៊ុំស្រីនៅឪពុកម្ដាយរបស់អ៊ុំស្រីមានលក្ខណៈផ្ទះគ្បឿងឬក៏ផ្ទះស្បៅអ៊ុំស្រី?
ខៈ ផ្ទះពីដើម។
កៈ បាទ!ៗផ្ទះអ៊ុំនៅជាមួយឪពុកម្ដាយរបស់អ៊ុំស្រី?
ខៈ ផ្ទះខ្ញុំប្រកអ៊ីនប៉ាង។
កៈ បាទ! ប្រកអ៊ីនប៉ាងហើយអញ្ជឹងជញ្ជាំងអីគេដែរអ៊ុំស្រី?
ខៈ ជញ្ជាំងស្លឹក។
កៈ បាទ! ជញ្ជាំងស្លឹកហើយអញ្ជឹងដំបូង?
ខៈ ដំបូងអ៊ីនប៉ាង។
កៈ ដំបូងអ៊ីនប៉ាងហើយគេហៅសង្កសីនិងមែនអ៊ុំស្រី?
ខៈ អត់ទេដំបូងអ៊ីនប៉ាងនិងម៉ង។
កៈ បាទ! ហើយអញ្ជឹងអាណាប។
ខៈ អាណាបអាស្បៀ។
កៈ ហើយអញ្ជឹងរណាបអាស្បៀហើយអញ្ជឹងជើងសសរឈើទៅ។
ខៈ ចាំ! ជើងសសរឈើ។ហើយនោះនៅសសរផ្ទះ។
កៈ នៅតែសសរ។
ខៈ ចាំ! នៅសល់សសរនិងហើយនិងគ្រោងវានិង។
កៈ បាទ! ហើយឥឡូវរលំអស់ហើយអ៊ុំស្រី?
ខៈ ចាំ!
កៈ
ហើយអញ្ជឹងអ៊ុំនិយាយពីដើមមកអ៊ុំបន្តវេនពីឪពុកម្ដាយត្បាញក្រមាហើយត្បាញហូលហើយនិងត្បាញអីនិងទៅ?
ខៈ ចាំ!
កៈ បាទ! ហើយអញ្ជឹងអ៊ុំបើធ្វើរលីស្លឹកត្នោតអីអ៊ុំអត់ចេះទេ?
ខៈ ចាំ! អត់ចេះទេ។
កៈ ហើយដូចក្ងូរស្កូរត្នោតអត់ចេះដែរ។
ខៈ អត់ចេះទេ។
កៈ
ហើយអញ្ជឹងកាលពីអ៊ុំនៅក្មេងហើយពេលដែរអ៊ុំបានចូលរៀនតើអ៊ុំមានក្ដីស្រមៃថាពេលដែរអ៊ុំស្រីរៀនចប់ហើយអ៊ុំស្រីចង់ក្លាយមានក្ដីស្រមៃកាលពីតូចថាចង់បម្រើការងារជាគ្រូបង្រៀនហើយគ្រូពេទ្យហើយដូចជាធ្វើទាហានហើយនិងធ្វើប៉ូលិសអីទេអ៊ុំស្រី?

ខ៖
ហើយបើនិយាយទៅខ្ញុំថាអញ្ចេកហើយបើសិនថារៀននិងវាចេះទៅណាស់គ្រាន់ថាអត់បានធ្វើអីហីចុះហើយឲ្យតែបានជួយក្នុងគ្រួសារនិង។
ក៖ បាទ! ឲ្យតែបានយល់ដឹងខ្លះៗ។
ខ៖
គ្រាន់ថាបានជួយអីខ្លះនៅក្នុងគ្រួសារហើយបានយល់ដឹងខ្លះៗនិងហើយបើយើងអត់មានលទ្ធភាពអត់បានទៅមុនទៀតហើយគ្រាន់តែបានមើលផ្ទះបានក៏អស់ចិត្តដែរ។
ក៖ បាទ! ហើយអញ្ចឹងអត់មានក្ដីស្រមៃអីធំជាងនិងទេ?
ខ៖
អត់មានទេហើយព្រោះអីយើងមើលទៅម៉ែឪយើងក្រព្រោះអីយើងក៏មិនអាចឡូតទៅមុខរួចដែរ។
ក៖ បាទ! ហើយអញ្ចឹងយើងធ្វើតាមសម្ថតភាពយើងមានតែប៉ុណ្ណឹង។
ខ៖ ចាំ!
ក៖ បាទ!ហើយយើងអត់អាចលើសពីសម្ថតភាពបាន។
ខ៖ ចាំ!
ក៖ បាទ!
ហើយអញ្ចឹងអ៊ុំស្រីមានពាក្យអីចងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយរបស់អ៊ុំថាឲ្យគាត់ខិតខំប្រឹងរៀនហើយនិងខិតខំប្រឹងធ្វើការងារអញ្ចឹងអ៊ុំស្រី?
ខ៖ ចាំ!
ហើយអញ្ចឹងបានខ្ញុំផ្ដាំផ្ញើរកូនជំនាន់ក្រោយនិងត្បាញរវីនិងឲ្យចេះទៅហើយក្រោយពេលអត់ពីខ្ញុំទៅហើយវាបានបន្តវេនពីខ្ញុំនិងទៅទៀត។
ក៖ បាទ!
ហើយអញ្ចឹងចៅវិញអ៊ុំស្រីពេលដែរគាត់បានធំឡើងឲ្យគាត់ខិតខំប្រឹងរៀនទៅអញ្ចឹង?
ខ៖ ចាំ!
សូមឲ្យចៅនិងខិតខំប្រឹងរៀនទៅហើយបើម្ដាយឪពុកគេចិត្តគេមិចខ្ញុំដឹងទេតែបើចិត្តខ្ញុំឲ្យខិតខំប្រឹងរៀនហើយបើម៉ែឪមានលទ្ធភាពទៅហើយចេះតែទៅទៅហើយបើអត់មានទេបានត្រឹមធ្វើការធ្វើអីនិងតិចតួចអញ្ចឹងទៅ។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំអត់មានផ្ដែផ្ដាំកូនចៅឲ្យខិតខំតស៊ូទេអ៊ុំស្រី?
ខ៖
ហើយខ្ញុំប្រាប់ដែរថាខំប្រឹងទៅធ្វើក្រោយពេលតំណែងពីអញនិងហើយបើសិនអត់ពីអញទៅកូនឯងឲ្យបានចេះអានឹងរហូតៗហើយទាល់តដល់កូនទៅទៀត។
ក៖ បាទ!
ហើយអញ្ចឹងបើអ៊ុំចង់ឲ្យគាត់ជៀសវាងអីគេដែរអ៊ុំស្រីដូចពីគ្រឿងញៀនហើយល្បែងស៊ីសងហើយនិងបងតូចបងធំអញ្ចឹងអ៊ុំស្រីចង់ប្រាប់ទៅគាត់ទេ?

ខ៖ ចាំ!ៗខ្ញុំសុទ្ធចិត្តឲ្យចេញពីអាគ្រឿងញៀននិងឲ្យផុតកុំឲ្យមានមកបៀបខ្លួនឲ្យសោះ។
ក៖ បាទ!
ខ៖ ខ្ញុំអត់ឲ្យរញ្ជែរញ្ជាអីទេ។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំស្រីមានអីចុងក្រោយទៀតអត់អ៊ុំស្រី?
ខ៖ អត់មានអីចង់បន្ថែមទៀតផងនិង។
ក៖ បាទ! ហើយអញ្ចឹងអ៊ុំស្រីមានតែប៉ុណ្ណឹងអត់ហើយអ៊ុំស្រី?
ខ៖ ចាំ! អស់ហើយ។
ក៖ បាទ!
ខ៖ ខ្ញុំផ្ដាំផ្ញើរតែប៉ុណ្ណឹងទៅណាស់អត់មានអីចង់និយាយទៀតអស់ពាក្យនិយាយហើយ។
ក៖ បាទ! មានតែប៉ុណ្ណឹងអត់មានអីចង់បន្ថែមទៀតទេ។
ខ៖ ចាំ!
ក៖ បាទ!
ហើយអញ្ចឹងជាចុងក្រោយខ្ញុំសូមអរគុណអ៊ុំស្រីដែរញែកពេលវេលាដ៏មានតម្លៃមកកាន់សាលា B Y U
យើងខ្ញុំណាអ៊ុំស្រី។ហើយអញ្ចឹងអ៊ុំអនុញ្ញាតឲ្យខ្ញុំយកសម្លេងអ៊ុំទៅឲ្យសាលាបានអត់អ៊ុំស្រី?
ខ៖ ធ្វើមិចធ្វើទៅស្រាចតែក្មួយឯងតា។
ក៖ បាទ! ហើយអញ្ចឹងអត់អីទេអ៊ុំស្រីណោះ។
ខ៖ ចាំ!
ក៖
ហើយអញ្ចឹងខ្ញុំសូមអរគុណអ៊ុំស្រីដែរអ៊ុំបានញែកពេលវេលាបានឲ្យខ្ញុំធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់អ៊ុំអញ្ចឹងណាស់ហើយសូមឲ្យមានសុខភាពល្អហើយនឹងសូមឲ្យគ្រួសារអ៊ុំចេះតែមានការរកស៊ីចេះតែកាកកកឡើងទៅអញ្ចឹងអ៊ុំស្រី?
ខ៖ ចាំ!ៗ
ក៖
ហើយអញ្ចឹងសូមឲ្យសម្រេចគ្រាប់បំណងហើយសុខភាពល្អនៅក្នុងគ្រួសារទាំងហើយនិងបងស្រីដែរអញ្ចឹងដែរហើយនឹងបងស្រី?
បងស្រី៖ ចាំ!
ក៖ ហើយអញ្ចឹងសូមអរគុណអ៊ុំស្រីហើយនិងបងស្រីសូមជំរាបលា។
ខ៖ ចាំ!
បងស្រី៖ ចាំ!